# ការសំភាសន៍របស់បងស្រី ស៊ុន សិទ្ធថា

កៈ អ្នកសំភាសន៍ឈ្មោះ រិទ្ធ សិនភីនិច្ច ខៈ អ្នកដែរត្រូវគេសំភាសន៍ឈ្មោះ ស៊ុន សិទ្ធថា

**ការសង្ខេបរបស់បងស្រី ស៊ុន សិទ្ធថា**

បងស្រី ស៊ុន

សិទ្ធថាគាត់គឺជាក្មេងម្នាក់ដែរបានកើតនៅក្នុងគ្រួសារមួយដែរមានជីវភាពខ្វះខាតទើបគាត់ដែរជាកូនស្រីត្រូវចេញទៅធ្វើការដើម្បីគ្រួសារហ្នឹងឪពុកម្ដាយតាំងពីរអាយុទើបទេដប់ប្រាំមួយឆ្នាំរហូតទាល់តែរូបគាត់មានស្វាមីហ្នឹងមានកូនចំនួនបីទើបគាត់បានចេញមករកស៊ីខ្លួនឯងវិញប៉ុន្តែមុខរបរកស៊ីរបស់គាត់ដូចជាមិនសូវជាមានភាពរីកចំរើននោះទេក៏គាត់ត្រូវតែខិតខំសម្រាប់កូនគាត់ទៀតដែររហូតគាត់ត្រូវចំណាកស្រុកដើម្បីទៅធ្វើការនៅឯប្រទេសថៃដើម្បីរកប្រាក់សម្រាប់ផ្គត់ផ្គង់គ្រួសារហើយហ្នឹងកូនៗរបស់គាត់រហូតគាត់ក៏ត្រូវមកស្រុកវិញដោយសារតែម្ដាយគាត់ទទួលមរណៈភាពគាត់មានកូនមួយដែរមានសុខភាពមិនសូវជាល្អដូចជាក្មេងដ៏ទៀតទេដោយសារបែបនេះធ្វើអោយគាត់ពិបាកក្នុងការចិញ្ចឹមបីបាច់ថែរក្សាព្រោះគាត់ជាក្មេងដែរមានសត្តិមិនល្អដូចជាក្មេងដ៏ទៃតែគាត់ក៏នៅតែខំតស៊ូដើម្បីកូនៗរបស់គាត់ដដែល ។

កៈ អូ ខេ

ចាសអញ្ចឹងថ្ងៃនេះនាងខ្ញុំថ្លែងអំណរគុណដល់អ្នកមីងដែរបានផ្ដល់ពេលវេលាសម្រាប់ការធ្វើបទបទសំភាសន៍អោយនាងខ្ញុំបានធ្វើការសំភាសន៍អ្នកមីងបានជាលើទីពីរចាសអញ្ចឹងដែលទីតាំងសំភាសន៍គឺនៅភូមិវាលនៅជិតអង្គថ្ងៃសំភាសន៍នេះគឺបានធ្វើឡើងគឺនៅថ្ងៃទីបួនខែប្រាំពីរឆ្នាំពីរពាន់ដប់ប្រាំពីរវេលាម៉ោងបួនដប់ប្រាំពីរនាទីហើយសំភាសន៍ដោយនាងខ្ញុំផ្កាលរិទ្ធ សិនភីនិច្ច ចាសអញ្ចឹងតើអ្នកមីងអាចជំរាបឈ្មោះអ្នកមីងបានដែររឺទេ?

ខៈ ឈ្មោះ ស៊ុន សិទ្ធថា ចាស!!

កៈ ស៊ុន សិទ្ធថា

ចាសអញ្ចឹងអ្នកមីងខ្ញុំចង់អោយអ្នកមីងរៀបរាប់ឈ្មោះរបស់អ្នកមីងហ្នឹងណាកាលពីរក្មេងហ្នឹងណាកាលពីក្មេងៗរហូតបានមកដ៏អ្នកមីងនៅក្នុងពេលនេះហ្នឹងណាកាលពីក្មេងហ្នឹងណារហូតបានមកដ៏ពេលនេះហ្នឹងណាដែរអ្នកមីងបានចង់ចាំនូវអ្វីខ្លះៗអញ្ចឹងហ្នឹងណា។

ខៈ

ពីរក្មេងមានអីទេកាលពីរក្មេងហ្នឹងពូកែតាដើរលេងហ្នឹងណាកាលហ្នឹងអាយុប្រហែលជាដប់ឆ្នាំ

អីហ្នឹងណាពូកែរដើរលេងពេកហ្នឹងណាម៉ាក់ក៏បានវ៉ាយទៅហ្នឹងណាគាត់ប្រាប់ថាមិនអោយទៅនណាយើង

រឹងទៅគាត់ក៏វ៉ាយទៅហ្នឹងណាហ្នឹងហើយដូចជាមិនមានអីទេកាលពីក្មេងហ្នឹងណាមានតែប៉ុនហ្នឹងទេណាគ្មានអីទេហើយហ្នឹងទៅរៀនអីអញ្ចឹងទៅហ្នឹងណាមានអីទេ។

ក៖ អញ្ចឹងម្តាយរបស់អ្នកមីងគាត់កាចមែន ?

ខ៖

កាចហ្នឹងណាទៅរៀនដឹងទៅរៀនមកពីរៀនគឺនៅតែផ្ទះហ្នឹងណាមិនមានរឿងអីផងហ្នឹងណា ។

ក៖

ចុះអញ្ចឹងពេលដែរអ្នកមីងមានវ័យជំទង់វិញតើអ្នកមីងបានធ្វើអ្វីខ្លះអញ្ចឹងហ្នឹងណាអាចរៀបរាប់បានដែររឺទេមីង?

ខ៖

ពេលដែរចាប់ផ្តើមអាយុដប់ប្រាំមួយឆ្នាំចាប់ផ្តើមចេញមកធ្វើការធ្វើការយកលុយអោយមកម៉ាក់អញ្ចឹងហ្នឹងណាដោយសារតែកាលហ្នឹងវាពិបាកខ្លាំងណាស់ណាកាលហ្នឹងពេលដែរអាយុបានដប់ប្រាំមួយឆ្នាំហ្នឹងណាចេញមកធ្វើការហ្នឹងណាចេញមកមករត់តុកន្លែងលក់កាហ្វេម៉ាក់គាត់យកមកដាក់នៅកន្លែងរត់តុកាហ្វេរត់តុកាហ្វេហ្នឹងបានឡើយពីរឆ្នាំណោះហ្នឹងណាបានឡើងពីរឆ្នាំបីឆ្នាំណោះហ្នឹងហូររត់តុកាហ្វេហ្នឹងបានឡើងយូរណោះហ្នឹងគិតទៅតាំងពីរអាយុដប់ប្រាំមួយហ្នឹងរហូតមកដំណាយកលុយមកអោយម៉ាក់កាលហ្នឹងពិបាកខ្លាំងណាស់កាលហ្នឹងខំប្រឹងធ្វើការយកលុយមកអោយម៉ាក់ហ្នឹងណាគិតទៅចាប់តាំងពីពេលដែរបានចេញពីរផ្ទះមកធ្វើការហ្នឹងណាមិនដែរចូលផ្ទះវិញទេហ្នឹងណាគិតទៅចាប់តាំងពីរអាយុដប់ប្រាំមួយហ្នឹងមកហ្នឹងណារហូតៗទាល់តែមានប្តីហ្នឹងណាប៉ុន្តែខ្ញុំក្រមានប្តីណាស់ណាយូរណាស់បានមានប្តីហ្នឹងណាអាយុឡើងម្ភៃប្រាំមួយហើយហ្នឹងណាបានមានប្តីហ្នឹងណាយូរណាស់មិនដូចជាក្មេងឥឡូវហ្នឹងទេឡើងអាយុដប់ប្រាំមួយឆ្នាំណោះហ្នឹងណាបានគេមានប្តីហ្នឹងណាក្មេងឥឡូវហ្នឹងតាដប់ប្រាំមួយដប់ប្រាំពីរដប់ប្រាំបីហ្នឹងគេមានប្តីអស់ទៅហើយហ្នឹងណាខ្ញុំវិញអត់ទេយូរណាស់ណាដោយសារតែខ្ញុំនៅដើរធ្វើការសិនហ្នឹងណាដំពេលដែរយើងឈប់ពីររត់តុកាហ្វេហ្នឹងទៅក៏យើងទៅរត់តុលក់ស៊ុនលក់អីទៅវិញហ្នឹងណារត់តុនេះនោះអីអញ្ចឹងទៅហ្នឹងណារួចដំតាពេលដែរយើងឈប់រត់តុនៅកំពង់ចាមអញ្ចឹងទៅហ្នឹងណាក៏ទៅរត់តុនៅភ្នំពេញវិញហ្នឹងណាទៅនៅដំភ្នំពេញវិញ

ទៅហ្នឹងណាក៏ទៅរត់តុអោយគេទៅទៅរត់តុតាមកន្លែងលក់ស៊ុបលក់អីទៀតទៅហ្នឹងណារត់តុស៊ុនរត់អីអស់ពីរហ្នឹងទៅទៅរត់អាតុអីគេកាលជំនាន់ហ្នឹងគរហៅប៉ែលហ្គាលឌិនប៉ែលហ្គាលប៉ែលអីហ្នឹងណាហ្នឹងអែង។

ក៖ ចាស!!!

ខ៖

ហ្នឹងហើយគេហៅថាអញ្ចឹងនោះអែងក៏នៅតែរត់តុអញ្ចឹងរហូតហ្នឹងណារត់តុអញ្ចឹងរហូតទាល់តែបានប្តីអញ្ចឹងបានឈប់ហ្នឹងណាបានប្តីទៅក៏ឈប់ទៅរួចទៅក៏រកស៊ីលក់ខោអាវជជុកលក់អី

អញ្ចឹង

ទៅហ្នឹងណាលក់នៅភ្នំពេញហ្នឹងណាលក់នេះលក់នោះលក់បាយតាមតែចង់ហ្នឹងទៅហ្នឹងណាមិនដឹងជាស្អីទេហ្នឹងណាលក់តាមតែចិត្តចង់ទៅហ្នឹងណាមិនដឹងជាលក់ស្អីៗខ្លះទេហ្នឹងណាតែដ៏តាម៉ាជំនាន់ដែរបានត្រឡប់មកនៅអីសៀមរៀបវិញហ្នឹងកាលបានមកនៅសៀមរាបដំបូងហ្នឹងបានមកលក់នែលក់ស្អីទេអឺហ្នឹងហើយលក់ចេកចៀនលក់ចេកចៀនលក់អន្សមអាំងអាំអៗទៅផ្ទុះខ្ទង់រលៀកមុខទៅហ្នឹងណារលៀកដៃរលៀកមុខហ្នឹងណាក៏ឈប់អាំងហើយហ្នឹងណាចេកចៀនៗទៅវាក្តៅដៃក្តៅអីហ្នឹងក៏ឈប់ចៀនហើយហ្នឹងណាហ្នឹងហើយធម្មតាយើងនៅរៀងក្មេងដែរវាមិនជាសូវដូចជាគេចាស់ហ្នឹងទេណារួចក៏មកលក់បបរលក់កាហ្វេលក់នំបញ្ចុកបាញ់ស៊ុងបាញ់អីអញ្ចឹងទៅអីវិញហ្នឹងណារួចទៅលក់ៗក៏ឈឺៗហើយព្រោះអីយើងវាធ្វើការធ្ងន់ពេកហ្នឹងណាដោយសារតែយើងលើអីវ៉ាន់អីៗធ្ងន់ពេកហ្នឹងណារួចឈប់ព្រោះអីយើងវាធ្វើការងារធ្ងន់ពេកហ្នឹងណាដ៏តាអញ្ចឹងទៅជាមកវិញឈប់លក់អាបបរអាអីហ្នឹងទៀតហ្នឹងណាព្រោះវាធ្ងន់ពេករួចទៅក៏បានដើមទៅមើលគេនៅហ្នឹងផ្សារលើនេះវិញក្នុងហ្នឹងប្រហែលជាកំឡុងឆ្នាំពីរពាន់ប្រាំកាលហ្នឹងកាលហ្នឹងអត់មានផ្ទះនៅទេកាលហ្នឹងជួលផ្ទះគេនៅទេណារួចទៅក៏បានដើរមើលគេចុះឡើងចុះឡើងហ្នឹងទៅហ្នឹងណារួចទៅក៏បែកគំនិតទៅលក់បន្លែទៅទិញហ្នឹងងើបពីរយប់ហ្នឹងម៉ោងបួនហ្នឹងណាងើបដើរមើលគេនៅហ្នឹងមុខផ្សារលើហ្នឹងណាកេយកបន្លែមកបោះអោយហ្នឹងណាដ៏តាហើយទៅហ្នឹងណាខ្ញុំក៏បានបែកគំនិតលក់បន្លែទៅហ្នឹងណា។

ក៖ ចាស!!!

ខ៖

កាលហ្នឹងមានលុយតែប៉ុន្មានម៉ឺនទេហ្នឹងណាទៅទិញបន្លែលក់មួយមុខបន្តិចមួយមុខបន្តិចហ្នឹង

ណាពីរនាក់បងថ្លៃដោយសារតែបងថ្លៃហ្នឹងគាត់ពូកែដឹងឥវ៉ាន់គាត់ពូកែជិះកង់ហើយដឹងតែកង់ហ្នឹងទេណា

រួចទៅគាត់តែដឹកឡើងពេញគាត់ពូកែជិះណាស់ណាមីងមិនចេះដឹងទេមីងជិះបានតែមួយខ្លួនហ្នឹងទេណានៅហ្នឹងណាក៏ពេលដែរលក់ៗអញ្ចឹងទៅហ្នឹងបានៗសន្សំលុយបានអញ្ចឹងហ្នឹងណារួចទៅក៏បាននៅៗអញ្ចឹងទៅហ្នឹងគាត់ក៏បានឈ្លោះគ្នាជាមួយហ្នឹងប្ដីប្រពន្ធគាត់ណោះគាត់ក៏បានឈប់លក់ទៅគាត់ក៏ទៅភ្នំពេញបាត់អែងនៅតែអែងហ្នឹងកុនបាត់ដឹងបន្លែវាមិនរួចចុះឡើងៗអញ្ចឹងទៅហ្នឹងណាឈប់បានលក់ហើយក៏ទិញបន្លែតែបន្តិចៗវិញព្រោះដឹងខ្លួនអែងមិនរួចតែបើយើងទិញបន្តិចៗហ្នឹងវាលក់វាមិនសូវបានចំណេញទេណាបានតែមួយម៉ឺនពីរម៉ឺប៉ុនហ្នឹងអែងរួចក៏លក់រហូតៗហ្នឹងទៅក៏បានទៅទិញអាម៉ោងពីរយប់ហ្នឹងណាម៉ោងពីយប់ក៏បានដើបទៅទិញហ្នឹងណាទៅទិញយូរៗទៅក៏ឈប់ទៅលក់ទៀតហើយហ្នឹងណាព្រោះអីម្នាក់អែងហ្នឹងណាខ្លាចណាស់រួចក៏បានទៅមកទៅមកក៏បានមកទៅលេងចានម្ហូបការទៀតហើយហ្នឹងណាដូចជាអត់មាននេះទេមានតែអីទេមានតែទៅលាងចានគេតាមកន្លែងញុំាការហ្នឹងណាគេចេះតែអោយធ្វើទៅហ្នឹងណាគេស្គាល់គ្នាៗហ្នឹងណាគេចេះតែហៅទៅតាមគេក៏ចេះតែទៅៗហ្នឹងណាដ៏តាបានលក់ៗទៅហ្នឹងក៏បានស៊ីឈ្នួលគេខ្លះអីខ្លះអញ្ចឹងទៅក៏បានឈប់នៅហ្នឹងទៅក៏បានទៅនៅអីខេត្តព្រះវិហារវិញតាសទៅនៅនោះប្ដង់ព្រោះនៅនេះដូចជាមិនសល់មិនអីសោះអញ្ចឹងហ្នឹងណាណាជួលផ្ទះជួលអីគេផងហ្នឹងណាតាមប្ដីមានអីទៅនៅទៅជួលផ្ទះគេហ្នឹងណារួចក៏បានទៅនៅអីខេត្តព្រះវិហារវិញហ្នឹងណាទៅខេត្តព្រះវិហារខាងស្រុកប្ដីគេមានដីមានអីអញ្ចឹងទៅហ្នឹងណារួចក៏ទៅប្ដីហៅទៅក៏ទៅនៅហ្នឹងទៅកាលហ្នឹងក៏រកបានកាក់កបដែរហ្នឹងណាកាលហ្នឹងទាហានវាចូលទៅវាយនៅអីប្រាសាទព្រះវិហារនោះកាលហ្នឹងលក់នេះលក់នោះអីអញ្ចឹងទៅហ្នឹងណាដាច់ណាស់ណាកាលហ្នឹងលក់កាហ្វេអីហ្នឹងណាដាច់ណាស់ណាបានសល់លុយច្រើនដែរហ្នឹងណាបានទិញដីទិញអីណាណីស្រាប់តែដីហ្នឹងគេដកអស់ទៀតសល់លុយច្រើនដែរហ្នឹងណាកាលពីមួយរុបហ្នឹងណាស់បានឡើងប៉ុន្មានពាន់ហ្នឹងពីរបាត់ដៃទទេហ្នឹងណាដ៏តាពេលដែរដីកំពុងតែមានហាងឆេងមនុស្សគេកំពុងតែនាំគ្នាចុះមកទិញគឺគឹបព្រោះអីដីវាមានហាងឆេងដែរអែងនេះសន្សំលុយបានហើយរួចក៏ទិញដែរហ្នឹងគេដែរតែមានបានទិញដែរតែមិនបានទិញជួរថ្នល់ទេព្រោះអីជួរថ្នល់វាថ្លៃកាលហ្នឹងពីរពាន់មួយពាន់ជាងអីហ្នឹងកាលហ្នឹងជួរបន្ទាប់ជាមួយហ្នឹងដីយើងហ្នឹងណាចេះតែទិញៗហ្នឹងណាវារៀងធូរថ្លៃហើយដ៏តាពេលដែរលក់បានមួយបួនប្រាំពាន់បួនប្រាំពាន់អីវិញហ្នឹងណាយើងចេះតែលក់វិញទៅហ្នឹងណាហ្នឹងអែងយើងទិញពីរ

ពាន់យើងលក់វិញបានបួនប្រាំពាន់យើងចំណេញយើងចេះតែលក់ទៅវិញទៅហ្នឹងណាគិតគ្នាជាមួយហ្នឹងប្តីហ្នឹងណាស្រាប់តែវាមានទាន់បានបួនប្រាំពាន់អីណាស្រាប់តែសភាពការប្រែប្រួលទៅជាអញ្ចឹងទៅវិញវាមិនដឹងជាយ៉ាងម្តេចស្រាប់តែគេដេញតំបន់ព្រះវិហារហ្នឹងទាំងអស់ទៅជាភូមិធម្មជាតិសម្តេចតេជោរហ៊ុនសែន
គេថាអាដីយើងហ្នឹងជាប់ពាក់ពាន់ជាមួយហ្នឹងអក្សរាដីយើងហ្នឹងណា។

ក៖ ចាស!!!

ខ៖
រួចក៏គេបានដេញអោយទៅនៅអីភូមិធម្មជាតិសម្តេចតេជោរហ៊ុនសែនហ្នឹងទៅណាតែគេមិនមែនយកទៅទទេរទេណាគេក៏បានដោះដូរអោយយើងហ្នឹងដែរណាតែគេដោះដូរ
ហ្នឹងគេមិនមែនដោះដូរអោយយើងហ្នឹងប៉ុណ្ណោប៉ុនហ្នឹងវិញណាគេអោយប៉ុណ្ណោយកតែប៉ុនហ្នឹងទៅណាយើងមានដីប៉ុន្មានៗទៅប៉ុនគេមានទៅប្តូរអោយយើងវិញណា។

ក៖ គេអោយមួយផ្ទះៗណោះ?

ខ៖
ចាស!!ហ្នឹងហើយអញ្ចឹងបានតែក្បាលហាសិបបណ្តាយមួយរយហ្នឹងដីហ្នឹងវាកន្លះហាត់ដែរហ្នឹងណាដីហ្នឹងនោះដីព្រៃទេតែបើដីយើងវិញនោះណាគឺជាដី
ចំការយើងមានស្វាយមានអីឡើងបានត្រឹមៗទ្រូងហើយហ្នឹងណាធំៗហើយហ្នឹងណាយើងមានអីស្វាយដែរយើងបានដាំនោះដាំបានឡើយមួយឆ្នាំជាងទៅហើយហ្នឹងណាស្វាយយើងដាំបានច្រើនដែរហ្នឹងណាបើសិនជាយើងនៅយើងវិញនោះបានល្អបាត់ហើយស្វាយយើងប្រកតជាផ្លែបាត់ទៅហើយហ្នឹងណាមួយរយដើមណោះហ្នឹងណាមួយរយដើមសិនជាផ្លែវិញហ្នឹងណាច្រើនដែរហ្នឹងណាផ្លែវិញយើងបេះយកទៅលក់វិញហ្នឹងណាបានមិនចេះតិចតោនទេហ្នឹងណាដ៏តាពេលដែរគេដេញអញ្ចឹងទៅគេមានបានអោយយើងវិញអាហ្នឹងវិញណាគេអោយតែដីយើងហាសិបម៉ែត្របនណ្តោយមួយរយម៉ែត្រហ្នឹងណារួចអោយមកហ្នឹងដីព្រៃទៀតរួចខ្ញុំខ្ជិក៏លក់ដីហ្នឹងបាត់ទៅហ្នឹងណាខ្ញុំខ្ជិលយក។

ក៖ អញ្ចឹងដីហ្នឹងពីមុននៅណាដែលនៅសៀមរាបដែររឺមួយក៏នៅព្រះវិហារដែរមីង?

ខ៖
ដីនៅអីព្រះវិហារហ្នឹងណាដែរគេបានដោះដូរមកអោយយើងវិញហ្នឹងណាហើយបើដីយើងនៅ

ហ្នឹងហើយយើងគេមិនប្តូរអោយយើងនៅហ្នឹងដែរដីហ្នឹងដែរថាមានពាកពាន់ជាមួយហ្នឹងអក្សរាហ្នឹងណា។

ក៖ ចាសអញ្ចឹងមីងនៅហ្នឹងបានប៉ុន្មានឆ្នាំដែរអ្នកមីង?

ខ៖

ចាប់តាំងពេលពេលដែរបានចេញមកពីនោះមកហ្នឹងមានណាយើងនៅតែទៅវិញទៅមកហ្នឹងណាព្រោះម៉ាក់ខ្ញុំនៅហ្នឹងចេះតែទៅមកទៅមកអញ្ចឹងហ្នឹងទៅហ្នឹងណាម៉ាក់ឈឺក៏មកកូនអីឈឺក៏មកហ្នឹងណារួចដ៏តា

ពេលដែរយើងឈប់នៅនោះរួចយើងបានមកនៅនេះពេញវិញហ្នឹងណាដូចជាចាប់ផ្តើមតាំងពីរឆ្នាំប៉ុន្មានទេដូចជាពីរពាន់ប្រាំបួនបើមិនពីរពាន់ប្រាំបួនទេពីរពាន់ដប់ហ្នឹងណាចាប់តាំងពីរឆ្នាំពីរពាន់ដប់មកហ្នឹងណាព្រោះម៉ាក់ខ្ញុំគាត់ស្លាប់ហ្នឹងណាបានជាមកនៅហ្នឹងជាប់រហូតមកទៅក៏ចាប់ផ្តើមនៅហ្នឹងជាប់បណ្តោយហ្នឹងណាមកនៅនេះវិញទៅព្រោះម៉ាក់ខ្ញុំមានដីនៅនេះដែរហ្នឹងណានៅហ្នឹងរហូតទៅហ្នឹងណារហូតទាល់តែឆ្នាំ២០១១ហ្នឹងបានៗទៅថៃហ្នឹងទៅណា។

ក៖ ទៅប្រទេសថៃ?

ខ៖

ហ្នឹងហើយពីរនាក់ប្តីប្រពន្ធនាំគ្នាទៅស៊ីឈ្នួលគេហ្នឹងនៅហ្នឹងថៃទាំងពីរនាក់ហ្នឹងទៅហ្នឹងណាពីរនាក់ប្តីប្រពន្ធគិតមើលទៅធ្វើអីដូចជាមិនកើតទេមើលទៅហ្នឹងនណារកធ្លាក់រកធ្លាក់អញ្ចឹងរួចក៏បានគិតថានាំគ្នាទៅថៃទៅអញ្ចឹងហ្នឹងណាបានប្រហែជាមួយឆ្នាំពីរឆ្នាំរួចក៏បានពោះធំមីអូនហ្នឹងណារួចក៏បានត្រឡប់មកវិញទៀតទៅហ្នឹងណារួចក៏មកនៅអញ្ចេកទៅហ្នឹងណាធ្វើការសំណង់អញ្ចឹងទៅហ្នឹងណាដីនេះរាល់ថ្ងៃហ្នឹងដីកេរ្តិ៍ម៉ាក់តាសរាល់ថ្ងៃខ្ញុំមានដីណាខ្ញុំ។

ក៖ អូ ដីកេរ្តិ៍ម្តាយណោះ?

ខ៖ ចាសហ្នឹងហើយ។

ក៖ រួចអញ្ចឹងឥឡូវហ្នឹងតើគាត់ស្លាប់យូរហើយនៅអញ្ចឹងមីង?

ខ៖

គាត់ស្លាប់យូរហើយហ្នឹងណាប្រហែលជាឆ្នាំពីរពាន់ដប់រឺក៏ពីរពាន់ដប់មួយទេនាគភ្លេចបាត់ទៅហើយហ្នឹងណា។

ក៖ ចាសហ្នឹងហើយអញ្ចឹងស្លាប់ឡើងប្រាំមួយប្រាំពីរឆ្នាំជាងទៅហើយហ្នឹងណោះ។

ខ៖ ហ្នឹងហើយយូរហើយហ្នឹងណាខ្ញុំភ្លេចបាត់ទៅហើយហ្នឹងណា។

កៈ អញ្ចឹងមីងផ្ទះនេះពីរមុនធំរឺក៏ទូចដែរមីង?

ខៈ ពីរមុនម៉ាក់គាត់នៅទូចទេតែអានេះយើងធ្វើខ្លួនឯងហ្នឹងណាពីរមុនទូចទេ។

កៈ អូ អញ្ចឹងឥឡូវហ្នឹងវារីកចំរើនជាមុនណោះ។

ខៈ

មានទេរកបានម៉ាទិចហ្នឹងក៏ធ្វើទៅរកបានម៉ាសារហ្នឹងក៏ធ្វើទៀតទៅហ្នឹងណារួចរកបានបន្តិចៗទៀតហ្នឹងក៏បានធ្វើមួយសារទៀតទៅហ្នឹងទៅធ្វើមែនចេះតិចដង។

កៈ ហ្នឹងហើយធ្វើមួយសារទៀតស្អាតជាមុនទៀតទៅហ្នឹងណា។

ខៈ

នេះបើសិនជាមានលុយវិញហ្នឹងណាតែរាល់ថ្ងៃហ្នឹងវាមិនមានហ្នឹងណាខ្ញុំវាយអាឥដ្ឋហ្នឹងចោលវិញអោយអស់ហ្នឹងណាពង្រីកអោយវាបានធំបន្តិចទៀតរហូតបានទៅដំសសរហ្នឹងទៅណាវាយដំតាអស់រួចយើងចាប់ផ្តើមចាក់សាបទៅហ្នឹងណាអោយវាបានធំបន្តិច។

កៈ

ហើយចុះសម្រាប់បងប្អូនមីងវិញហ្នឹងណាបងប្អូនបង្កើតមីងហ្នឹងណាតើមានអ្នកណាធ្វើអោយមីងថ្នាំថ្នាក់ចិត្តដែររឺទេមីងរហូតទាល់តែមកដំសព្វថ្ងៃហ្នឹងអត់មីង?

ខៈ មានតាមានប្អូនរាល់ថ្ងៃហ្នឹងមាននិយាយរកគ្នានណា។

កៈ មូលហេតុអីទៅមីង?

ខៈ

គ្មានអីទេតែគេមិននិយាយខ្ញុំគ្មានបានធ្វើអីគេទេណាគេចេះតែមិននិយាយជាមួយយើងហ្នឹងណាតែបើសិនជានិយាយទៅហ្នឹងណាវាព្រាបដូចជាថាខ្លួនឯងចោរហើយតែមិនប្រាប់ថាខ្លួនឯងហ្នឹងជាចោលទៅហ្នឹងណាហ្នឹងហើយនិយាយទៅវាចូលទៅន័យអញ្ចឹងៗឯងមើនិយាយទៅថាឯងហ្នឹងថាតាឯងត្រូវហ្នឹងណាដូចថាគេវាចេះតែខុសហ្នឹងណាតែតាយើងនិយាយទៅគេវាចេះតែត្រូវអាឯងហ្នឹងវាចេះតែខុសទៅហ្នឹងណាអញ្ចឹងក៏ខ្ជិលនិយាយតែម្តងទៅហ្នឹងណាដូចថាមនុស្សវាមាននិស្ស័យមិនដូចគ្នាហ្នឹងណាហើយតែនិស្ស័យវាមិនដូចគ្នាហើយហ្នឹងណាគឺថាវាមិនត្រូវគ្នាទេហ្នឹងណានិយាយក៏មិនត្រូវគ្នាដែរហ្នឹងណា។

កៈ ចាសចុះអញ្ចឹងតើអ្នកមីងមានអារម្មណ៍ថាគុំគួនគាត់ដែររឺទេមីង?

ខៈ អត់ទេខ្ញុំគ្មានគុំអីទេគ្រាន់តែខ្ញុំហ្នឹងវាខ្ជិលហ្នឹងណា។

កៈ ចាសមីងធ្វើអញ្ចឹងល្អអ្នកមីង។

ខ៖

ខ្ញុំគ្មានគុំគ្មានអីទេព្រោះអីខ្ញុំវាខ្ជិលហ្នឹងណាមិនឃើញទេអីមើលកូនវាមកអីធម្មតាហ្នឹងណាមិនខ្វះទេមានលុយរឺក៏អត់លុយអីនៅតែផ្ទះយើងហ្នឹងទៅណាមិនខ្វះ

ទេនៅតែក្នុងផ្ទះយើងហ្នឹងទៅណាព្រោះថាមនុស្សវាហ្នឹងនិស្ស័យវាមិនត្រូវគ្នានជាមួយហ្នឹងយើងផងហ្នឹងណាបើអ្នកនៅជិតហ្នឹងវាឈ្លួសជាមួយហ្នឹងគេគ្រប់តែមនុស្សទាំងអស់ហ្នឹងណាមួយជួរហ្នឹងទាំងអស់វាគ្មាននិយាយជាមួយហ្នឹងណាគេមួយផងហ្នឹងណានៅម្ដុំវាហ្នឹងណាវាគ្មានត្រូចគ្មានជាមួយអ្នកណាម្នាក់ទេថ្ងៃមុនហ្នឹងវិញណាគេនាំគ្នាព្រួសវាយចង់ងាប់ទៅហើយហ្នឹងណា។

ក៖ ប្អូនរបស់មីងហ្នឹងមែន?

ខ៖

ហ្នឹងហើយប្អូនខ្ញុំអាប្រុសហ្នឹងណាវាស្រវឹងហ្នឹងណាគ្មានដឹងអីទេគេនាំគ្នាព្រួតវាយចង់ងាប់ទៅហើយហ្នឹងណាវាស្រវឹងប៉ែឡែដើរតែរករឿងគេហ្នឹងណាវាជារឿងធម្មតាទៅហើយហ្នឹងណា។

ក៖ ចាសអូណោះ ។

ខ៖

ចាសហ្នឹងហើយវាតែប៉ុណ្ណឹងទៅហើយហ្នឹងណាបើនិស្ស័យរបស់ពួកវាតែប៉ុណ្ណឹងទៅហើយហ្នឹងណាជាទំលាប់របស់វាទៅហើយដ៏តាគេវាមិនត្រូវជាមួយហ្នឹងគេទៅហើយ

ហ្នឹងណាអញ្ចឹងគេចេះតែថាយើងអញ្ចេកយើងចុះទៅហើយហ្នឹងណា។

ក៖ ចាសហ្នឹងហើយអញ្ចឹងអ្នកមីងនៅតែមានសេចក្ដីស្រលាញ់ជាមួយហ្នឹងគេបំផុតណោះ?

ខ៖

ហ្នឹងហើយធម្មតាបើយើងមានអីស៊ីក៏ចេះតេយកទៅអោយកូនវាស៊ីហ្នឹងទៅហ្នឹងណាមិនទៅដែរថាអញ្ចេកអញ្ចុះអីហ្នឹងទេណាមិនចេះថាគុំគួនអីទេខ្ញុំហ្នឹងណា។

ក៖ ចុះអញ្ចឹងសម្រាប់ស្វាមីរបស់អ្នកមីងវិញថាតើគាត់គឺចាមនុស្សបែបណាដែរអ្នកមីង?

ខ៖

គាត់មិនស្ងូវចេះមានមិនចេះករអីផងហ្នឹងណារួចមិនជាស្ងូវចេះនិយាយអីដែរហ្នឹងណាមកពីរធ្វើការវិញក៏បានបាយបាយរួចក៏សម្រាកទៅហ្នឹងណា។

ក៖ ហើយចុះអញ្ចឹងដូចជាការញុំម្ហូបអីគាត់ដូចជាមិនជាស្ងូវពិបាកទេណោះមីងណោះ?

ខ៖ គាត់ចូលចិត្តតែត្រៀមៗហ្នឹងណា

តែបើសិនជាសម្លេរអីវិញហ្នឹងណាមានទេគាត់ចូលចិត្តតែហូបម្តងម្កាលហ្នឹងណាយូរៗម្តងអីហ្នឹងទេចូលចិត្តជាងគេគឺសាច់អាំងហ្នឹងណាសាច់គោយកមកអាំងសាច់

គោហ្នឹងអាំងមានអាំងអោយស្ងួតរួចកុំប្រឡាក់ទេហ្នឹងណារួចយកមកជ្រលក់ជាមួយហ្នឹងទឹកម្ទេសទឹកអីហ្នឹងជ្រលក់ទៅហ្នឹងណាហ្នឹងហើយអាហ្នឹងគាត់ចូលចិត្ត។

ក៖

រួចចុះអញ្ចឹងបង្វែរមកដ៏កូនៗរបស់អ្នកមីងអញ្ចឹងហ្នឹងណាសម្រាប់កូនៗរបស់មីងទាំងអស់ហ្នឹងអញ្ចឹងតើក្នុងចំណោមកូនៗរបស់មីងទាំងអស់គ្នាហ្នឹងតើកូនរបស់មីងមួយណាដែរពិបាកក្នុងការចិញ្ចឹមជាងគេ?

ខ៖ ពិបាកចិញ្ចឹងហ្នឹងវាម្តេចដូចជាម្តេចដែរឈឺច្រើនរឺក៏ម្តេច?

ក៖ ហ្នឹងហើយពិបាកចិញ្ចឹមហ្នឹងដូចជាឈឺច្រើន?

ខ៖

មានតាអាកូនទីពីរហ្នឹងណាកើតមកបានតែកន្លះខែហ្នឹងក៏ចាប់ផ្តើមឈឺរហូតមកហ្នឹងណាវាមិនសូវជាដឹងអីទេណាវាមិនគ្រប់ទឹកផងហ្នឹងណាកើតមកបានតែកន្លះហើយហ្នឹងណាវាក៏ចាប់ផ្តើមឈឺរហូត

មកហ្នឹងណា។

ក៖ អញ្ចឹងចាប់ពីរកើតមកហ្នឹងឈឺរហូតណោះមីង?

ខ៖

ចាសហ្នឹងហើយចាប់ពីរកើតមកបានតែកន្លះខែហ្នឹងចាប់ផ្តើមឈឺរហូតមកហ្នឹងណាដេកនៅពេទ្យកុមារតែរហូតហ្នឹងណាដេកបានតែពីរបីថ្ងៃចេញមកផ្ទះពីរបីថ្ងៃទៀត

ទៅពេទ្យវិញទៀតទៅហើយហ្នឹងណារួចដេកបានបួនប្រាំថ្ងៃចេញមករួចក៏ចូលពេទ្យទៀតអញ្ចឹងរហូតអញ្ចឹងរហូតទាល់តែអាយុបានមួយឆ្នាំតែនៅតែទៅមកទៅមកមួយខែម្តងមួខែម្តងរហូតមកហ្នឹងណារួចទៅគេក៏បានពិនិត្យអាបញ្ជីរគរហ្នឹងណាទៅមកទៅមករហូតហ្នឹងណាមួយសន្លឹករាល់ខែអញ្ចឹងទៅហ្នឹងណារួចខ្ញុំក៏បានចេះតែស៊ក់ចូលទៅក្នុងស៊ីមីរបស់គេហ្នឹងទៅណារាល់តែខែហ្នឹងណាទាល់តែគាត់ឈប់ដេកពេទ្យហ្នឹងណាបានខ្ញុំឈប់ស៊ក់ទៅហ្នឹងទៅហ្នឹងណា។

ក៖

អញ្ចឹងទាល់តែគាត់ឈប់ដេកពេទ្យហ្នឹងទៅបានមីងទាល់តែគាត់ហ្នឹងមានអាយុមួយឆ្នាំណោះ?

ខ៖
ចាសហ្នឹងហើយទាល់តែបានមួយឆ្នាំបានឈប់ទៅដេកពេទ្យវាឈឺដែរតែគ្រាន់តែពេលដែរយើងដាក់ថ្នាំទៅបានវាជាហ្នឹងណាដ៏តាអញ្ចឹងទៅវាក៏លែងបានទៅដេកនៅ
ពេទ្យហើយហ្នឹងណាកុំអីកាលពីមុនឈឺហើយហ្នឹងណាជូនការឡើងអញ្ចឹងហ្នឹងណាមើលទៅដូចថាវារៀងយ៉ាប់ខ្លាំងមែនទែនហើយហ្នឹងណារួចយកទៅដំពេទ្យទៅពេទ្យបានតែមួយភ្លេតកន្លាប់ភឹងតែម្តងហ្នឹងណាកន្លាប់
លេងហ្នឹងណាដេកធ្វើមិនដឹងវាពីនេះទៅដូចថាចង់ងាប់ហើយហ្នឹងណាកូនរួចលើកក្រោយៗមកចេះតែទុក្ខៗចោលទៅហ្នឹងទុក្ខអោយអែងចង់ងាប់តែម្តងទៅហ្នឹងណាទុក្ខតាមតែដំណើរតែម្តងទោទុក្ខអោយអែងងាប់តែន្តងទៅហ្នឹងណាឈឺម្តងៗឡើងស្លឹរួចទៅក៏ចេះតែខ្វិលណាមួយកូនហ្នឹងវាមិនសូវជាដឹងអីផងហ្នឹងណាពេទ្យប្រាប់ថាវាអត់គ្រប់ទឹក។
ក៖ ចាសអញ្ចឹងសម្រាប់សព្វថ្ងៃវិញគាត់នៅហ្នឹងទេ?
ខ៖ អូឥឡូវនៅព្រះវិហារណោះនៅអីខេត្តព្រះវិហារតាស។
ក៖ គាត់នៅជាមួយហ្នឹងពីរណាគេដែរ?
ខ៖
គាត់នៅជាមួយហ្នឹងយាយគេមកពីរគ្មានពីរណាគេជូនមកវិញហ្នឹងណារួចក៏អោយនៅហ្នឹងទៅហ្នឹងណា អោយអែងទៅយកតែអែងវាគ្មានពេលហ្នឹងណា។
ក៖ អូ!! ចាស អញ្ចឹងឥឡូវហ្នឹងក៏នៅតែអញ្ចឹងរហូតទៅណោះមីងណោះ?
ខ៖ ហ្នឹងហើយនៅតែអញ្ចឹងតាសឥឡូវហ្នឹង។
ក៖ អូ !! ចាស
អញ្ចឹងសម្រាប់ទៅថ្ងៃអនាគតរបស់ពួកគាត់តើអញ្ចឹងតើមីងចង់អោយកូនៗរបស់មីងធ្វើតាមបំណងរបស់មីងរឺក៏ក៏ជាកាសំរេចចិត្តរបស់ពួកគាត់ដែរមីង?
ខ៖ អូ
ពួកវាមិនអាចធ្វើតាមយើងបានទេរាល់ថ្ងៃនេះគិតថាខំប្រឹងតែចិញ្ចឹមពួកវាអោយបានធំៗទៅហ្នឹងណារួចអនាគតពួកវាចង់ធ្វើអីក៏ធ្វើទៅហ្នឹងណា។
ក៖ ចាស!!!

ខ៖
មើលតែប៉ុនៗហ្នឹងពិបាកនិយាយពួកវាសិងងាប់ទៅហើយដ៏តាពួកវាធំទៅកើតរឺក៏មិនកើតក៏តាមតែដំណើរវាទៅហ្នឹងណាព្រោះថាយើងរាល់ថ្ងៃនេះខំអស់ប៉ុណ្ណឹង
ទេហើយប្រាប់វាថាអោយខំៗទៅហ្នឹងណាតែវាមិនដឹងម្តេចទេក៏តាមដែរដំណើរវាទៅហ្នឹងណាហើយមើលទៅវាដូចជាមិនខំអីសោះថ្នាក់ទីពីរហ្នឹងឌុបពីរឆ្នាំទៅហើយហ្នឹងណាដូចជាមិនឃើញវាខំអីសោះ។
ក៖ ចាសអញ្ចឹងតើមីងមានវីធីសាស្រ្តអ្វីដែរដើម្បីចិញ្ចឹមកូនបានមកដំពេលនេះទេមីង?
ខ៖
ដូចជាគ្មានវីធីសាស្រ្តអីទេចិញ្ចឹមតាមតែធម្មជាតិហ្នឹងណាគ្មានវិធីសាស្រ្តអីទេបើយើងក្រហ្នឹងណាពេលដែរមានអីអោយញុំាក៏បានញុំាទៅអីមានក៏អត់ទៅហ្នឹងណា។
ក៖ ចាសអញ្ចឹងអ្នកមីងក៏នៅតែមានសេចក្តីស្រលាញ់ចំពោះពួកគាត់ណោះ?
ខ៖ អើយ ធម្មតាទេណាយើងវាជាម្តាយរបស់គេហ្នឹងណា។
ក៖
ចុះសម្រាប់បញ្ហាជីវិតវិញខ្ញុំក៏បានដឹងថាមីងពិតជាជួបនៅបញ្ហាច្រើនហើយអញ្ចឹងណាដូចដែរខ្ញុំបានស្តាប់ពីរមុនមកអញ្ចឹងហ្នឹងណាអញ្ចឹងសម្រាប់អ្នកមីងតើអ្នកមីង
មានគិតថាអ្នកមីងហ្នឹងចុះចាញ់នៅបញ្ហាអស់ទាំងហ្នឹងដែររឺទេមីង?
ខ៖
ពេលខ្លះមានណាចេះតែបាត់ទឹកចិត្តចង់ចុះចាញ់ម្តងៗដែរតាសរួចទៅក៏ចេះតែខ្វិលខំព្រោះអីវាសនាយើងទេវតាកំណត់មកអញ្ចឹងទៅហើយហ្នឹងណាទេវតាថាអោយយើងតែប៉ុណ្ណឹង
ទៅហើយហ្នឹងណាព្រោះអីតាមតែយើងខំប្រឹងរកខំសន្សំៗអញ្ចឹងទៅហ្នឹងក៏បានចាប់ផ្តើមធ្លាក់ព្រឹមរួចវាធ្លាក់ពីរបញ្ហារអ្វីមួយផ្សេងៗពីគ្មានអញ្ចឹងទៅហ្នឹងណាអញ្ចឹងបានខ្វិលសង្ស័យហ្នឹងណាព្រោះអីទេវតាបានកំណត់ហើយថាមិនអោយយើងហ្នឹងមានហ្នឹងណាវាមិនអាចមានទេគឺមានតែប៉ុណ្ណឹងទេណាបានតែមួយស៊ីៗហ្នឹងទៅណារួចមានពេលខ្លះទៅយើងចេះតែគិតទៅថាយើងមិនបាច់ខំទេណាធ្វើតែតាដំណើរទៅដូចជាពេលខ្លះទៅហ្នឹងណាដូចអាមួយសារនេះមានទេចេះតែអធិដ្ឋាៗទៅថាព្រះម្តេចក៏កូនពិបាកម្ល៉េះរាល់ថ្ងៃនេះពិបាកណាស់ដូចថាខ្វះអើយខ្វះមានណាស្រាប់តែនៅស្ងៀមៗពេលថ្ងៃរួចក៏កាលហ្នឹងអែលឌីគេមកគេថាមីងជំរាបសួរ
រួចពេលហ្នឹងខ្ញុំគិតថាណាគេទេខ្ញុំដូចជាមិនដែរស្គាល់ទេនាគ។

កៈ អញ្ចឹងមីងមិនដែរស្គាល់គាត់សោះតែម្តងណោះ ?
ខៈ ហ្នឹងហើយមិនដែរស្គាល់សោះហ្នឹងណា
រួចទៅខ្ញុំធ្វើមុខឆ្ងល់រួចគេហ្នឹងក៏បានរៀបរាប់ប្រាប់មកខ្ញុំវិញទៅថាខ្ញុំហ្នឹងទើបតែបានបញ្ចប់នៅបេសកកម្មឥឡូវហ្នឹងគេមានវគ្គបើបង្រៀនថ្នាក់ខ្លួនទីពឹងខ្លួន
អញ្ចឹងទៅហ្នឹងណារួចទៅអែងវាគ្មានអីទេរួចក៏បានគេហ្នឹងជួយអែងទិញអីៗធ្វើអីអញ្ចឹងទៅហ្នឹងណារួចទៅពេលហ្នឹងក៏បានចាប់ផ្តើមហ្នឹងឃើញថាអញ្ចេកថាអូប្រាកដជាព្រះជួយបង្ហាញផ្លូវអោយអញ្ចឹងហើយនាគមើល
ទៅដោយសារតែព្រះគាត់មិនធ្វើអោយពួកយើងអស់សង្ឃឹមហ្នឹងណារួចក៏បានខិតខំប្រឹងប្រែងតស៊ូមួយសារទៀតតស៊ូមួយសារទៀតរួចឥឡូវហ្នឹងវេទនាមួយសារទៀតទៅហើយហ្នឹងណាចេះតែតស៊ូទៅណារួចក៏សង្ឃឹមថាវាហ្នឹងកើតមានពិតប្រាកដមែនរួចក៏បានរៀនថ្នាក់ខ្លួនទីពឹងខ្លួនហ្នឹងបានចប់ហើយហ្នឹងណាចង់បញ្ចុះផ្សិតក៏គេទិញឧបករណ៍អោយយើងអស់ពីរយដុល្លារគ្រាន់តែអាសំភារះបណ្តុះហ្នឹងយើងទិញខ្លួនអែងស្រាប់តែគ្មានលុយទិញព្រោះអីគិតខុសគិតខុសថាគិតឃើញថាអញពិបាកទៀតហើយអញគិតថាបើយើងទិញអាសំភារះផលិតទៅហ្នឹងណាតែយើងមានទាន់បណ្តុះអាផ្សិតហ្នឹងមានទាន់ដុះផងហ្នឹងណា។
កៈ ចាស!!ហ្នឹងហើយ។
ខៈ
ដុះហើយតែវាដុះអត់បានល្អដំរួចទៅក៏បាននឹកឃើញថាអត់មានលុយទិញអាស្អីៗនេះហ្នឹងណាទិញនេះទិញនោះអីអញ្ចឹងហ្នឹងណាចេះតែទិញទៅហ្នឹងណាទិញមេផ្សិតផងទិញអីផងទៅហ្នឹងណាអត់ទិញចំបើងផងទិញមេផងទិញក្រណាត់កៅស៊ូផងអីហ្នឹងណាមានលុយទិញរួចក៏ទិញជំពាក់គេខ្លះអោយគេខ្លះអញ្ចឹងទៅណាខ្ញីលុយម៉ែថាវីផងខ្ញុំយកទៅទិញកៅស៊ូផងហ្នឹងណា ម៉ែអាសានផងហ្នឹងណាគេចេះតែអោយ
ខ្ញីទៅហ្នឹងណាម៉ែអាសានគេក៏បានអោយខ្ញីលុយហ្នឹងបានហាសិបម៉ឺនរួចគេក៏បានអោយខ្ញុំយមកហ្នឹងណារួចក៏បានយកទៅទិញអីទិញអីទៅណាហ្នឹងណាគេអោយខ្ញីបានដប់ម៉ឺនរួចក៏ទិញអីៗទៅណាម៉ែអាវិតរួចទិញនេះទិញនោះហើយដើរតែសងគេវិញរាល់ថ្ងៃនេះខ្លះដើរសង់បំណុលគេខ្លះតាថ្ងៃអាទិត្យហ្នឹងណាមិនហ៊ានហ្នឹងឈប់ផងហ្នឹងណាចេះតែនឹកឃើញថាយើងវាជំពាក់គេវាច្រើនហ្នឹងណារួចក៍ចេះតែនឹកឃើញថាអញវេទនាទៀតហើយដូចជាមិនបានសំរេចដូចជាបំណងសោះអាលុយក៏ជំពាក់គេអាផ្សិតនោះក៏មិនចេះជាផ្សិតទៀតរួចឥឡូវហ្នឹងក៏ចាប់ផ្តើមប

ណ្តុះនៅហ្នឹងក្នុងហ្នឹងហើយឥឡូវគេក៏បានមកមើលដែរហើយហ្នឹងណារួចមើលទៅឥឡូវហ្នឹងបានដុះបន្តិចៗហើយតែគ្មានហ្នឹងណាក៏ព្យាយាមជួយយើងហ្នឹងដែរហ្នឹងណាអោយតែបានរូបមន្តអីថ្មីៗមកហ្នឹងណាចេះតែយកមកប្រាប់យើងហ្នឹងហើយណាយកមប្រាប់ទៅណាថាធ្វើអញ្ចេកធ្វើអញ្ចេករួចដ៏តាឥឡូវហ្នឹងវាដុះមែនហ្នឹងណាព្រោះធ្វើតាមតែអារូបមន្តថ្មីប្លែកទៀតហើយហ្នឹងណាមីងសាកធ្វើទៅមើលណាមីងណាហ្នឹងណាធ្វើតែមួយកាឆេរទេទេដុះឡើរទ្រុបៗណោះហ្នឹងណាប៉ុន្តែយើងវាមិនមានលុយណាដាក់អោយបានច្រើនហ្នឹងណាប៉ុន្តែតាយើងមានលុយហើយហ្នឹងណាយើងចាប់ផ្តើមទិញចំបើងមកណារួចចំបើងមួយគោយន្តគេដប់ម៉ឺនជាងឥឡូវហ្នឹងយើងតីញចំបើងមកហើយហ្នឹងយើងក៏ចាប់ផ្តើមដាក់ទៅហ្នឹងណា

នេះៗកកយើងហើយហ្នឹងណាវាមានទៅណារួចទេវាចាប់ផ្តើមស្ទូះទៅហើយហ្នឹងណារួចទៅក៏ចេះតែនឹកឃើញហ្នឹងថាអូអញអើយបើសិនជាកុំទិញអាសំភារះបណ្តុះផ្សិតហ្នឹងវិញណារួចសុំអោយគេជួយទិញអាអីវ៉ាន់អីហ្នឹងគ្រប់មុខហ្នឹងវិញហ្នឹងគ្រប់មុខមកហ្នឹងណាអញ្ចឹងយើងមិនបានធ្វើណោះមិនអញ្ចឹងមែនទេណោះ។

ក៖ ចាស!!!ហ្នឹងហើយចាស។

ខ៖

ហ្នឹងហាលយឥឡូវហ្នឹងខំប្រឹងធ្វើវាអោយបានមួយជំហានទៀតហើយហ្នឹងណាចេះតែគិតទៅថាថ្ងៃក្រោយបើសិនជាតែមិនជាចង់មានស្អីគេខ្លាំងពេកទៅណាទេបើសិន

ជាខំបណ្តុះផ្សិតបានដុះល្អអោយបានលក់ត្រឹមតែពីរបីម៉ឺនហ្នឹងទៅណាបានហើយ។

ក៖ ចាស!!!ហ្នឹងហើយ។

ខ៖

ហ្នឹងហើយរួចដ៏តាប្តីយើងធ្វើការមកវាបានសល់ខ្លះហើយណាអញ្ចេកព្រោះអីវាល់ថ្ងៃហ្នឹងណាចំណូលហ្នឹងវាចូលតែមួយទេស៊ីចាយអីហ្នឹងលើទាំងអស់ហ្នឹងកូនចាយកូនអីហ្នឹងអត់មានបានសល់មួយរៀលនៅហ្នឹងខ្លួនសោះមិនដែរបានសល់នៅក្នុងខ្លួនទេមិនដែរបានសល់ទេគ្មានបានមួយរៀននៅក្នុងខ្លួនទេហើយយើងចេះទៃគិតថាប់សិនជាយើងឈឺធ្ងន់វិញរឺក៏បញ្ហារអ្វីមួយដែរបន្ទាន់វិញហ្នឹងណាគឺថាគ្មានលុយមកពីរណាទេមានតែអាលុយផ្សិតហ្នឹងណាអញ្ចឹងបានចេះតេខំប្រឹងធ្វើទៅហ្នឹងណាដើម្បីអោយតែវាកើតទៅហ្នឹងណាបើសិនជាមួយថ្ងៃខំប្រឹងបណ្តុះផ្សិតហ្នឹងអោយបានដុះល្អទៅហ្នឹងណារួចលក់វាបានតែពីរបីម៉ឺនហ្នឹងទៅណាល្អហើយរួចបានទប់ទល់នៅក្នុងក្រុមគ្រួសារទៅហ្នឹងណាហើយបានប្តីយើងរកមកទៀតទៅបានគ្រាន់ធ្វើការមកវាបា

នសល់អញ្ចេកព្រោះរាល់ថ្ងៃហ្នឹងចំណូលចូលទេមួយទេអញ្ចឹងមិនដែរមានបាននៅសល់មួយរយមួយរៀននៅហ្នឹងខ្លួនទេចាសអញ្ចឹងបានថាខំប្រឹងជាមួយហ្នឹងអាផ្សិតហ្នឹងណាមួយថ្ងៃបានតែមួយម៉ឺនហ្នឹងណាក៏យកដែរព្រោះអីទុក្ខសម្រាប់ដោះស្រាយជីវភាពនៅក្នុងគ្រួសារនេះហ្នឹងណាបានគ្រាន់រួចម្ហូបរួចអីរាល់ថ្ងៃហ្នឹងទៅម្តេចក៏បានរៀងគ្រាន់ដែរម្តេចក៏បានសល់អាប្រាក់ខែប្តីមួយខែៗបានពីររយជាងដែរហ្នឹងណាអញ្ចឹងក្នុងមួយខែមួយខែម្តេចក៏យើងបានសល់អាហ្នឹងដែរអាហ្នឹងបើសិនអញ្ចឹងមែនវាបានសល់ទៅគ្រាន់ហ្នឹងបានទប់ទន់នៅក្នុងក្រុមគ្រួសារយើងហ្នឹងដែរហ្នឹងណាហើយយើងនេះក៏បានចំណុលមួយទៀតទៅហ្នឹងណាចេះមិនដឹងមិចហែងមើលមួយខែជាងជិតពីរខែទៅហើយហ្នឹងណាបានចេះតែមិនអស់សង្ឃឹមដែរហ្នឹងណាចេះតែនឹកឃើញថាគិតអធិដ្ឋានសុំអោយព្រះជួយបើកផ្លូវបើកគំនិតខ្ញុំហ្នឹងណាអោយគិតនៅអ្វីដែរត្រឹមត្រូវបន្តិចទៅហ្នឹងណាកុំអោយគិតតែរឿងដែរខុសរហូតអីហ្នឹងណាឥឡូវម្តងហ្នឹងប្រហែលជាបានត្រូវហើយអញ្ចឹងហ្នឹងណាព្រោះអីខ្ញុំគិតច្រើនណាស់ណាចាសអញ្ចឹងម្តងហ្នឹងប្រហែលជាខ្ញុំគិតបានត្រឹមត្រូវហើយព្រោះអីវាដុះបានល្អហ្នឹងបានច្រើនណាស់។

ក៖

ចាសអញ្ចឹងទាំងអស់ហ្នឹងវាគឺជាក្តីសង្ឃឹមរបស់អ្នកមីងណោះទោះជាវាពិបាកប៉ុន្តែមីងបានស្គាល់ពីរស់ជាតិមួយហ្នឹង ចាស!!។

ខ៖ ហ្នឹងហើយខ្ញុំហ្នឹងខិតខំតស៊ូជាមួយហ្នឹងវាហ្នឹងណា។

ក៖

ចាសហើយខ្ញុំបានដឹងថានៅពេលដែរអ្នកមីងនិយាយអញ្ចឹងហ្នឹងណាកូនៗរបស់អ្នកមីងហ្នឹងបានលឺពីរសំដីរបស់អ្នកមីងហើយកូនៗរបស់អ្នកមីង

ហើយអញ្ចឹងមីងមានអីដែរត្រូវនិយាយទៀតអត់?

ខ៖ អត់មានទេមិនដឹងត្រូវនិយាយស្អីទៀតផង ។

ក៖

ចាសអញ្ចឹងអូខេយើងចង់អោយអ្នកមីងដូចជាចង់សំណូមពរជាចុងក្រោយហ្នឹងណាចង់អោយពួកគាត់ទាំងអស់គ្នាហ្នឹងបានស្តាប់លឺអីដែរទៅអោយកូនចៅរបស់អ្នកមីងអោយអ្នកមីងជួយសំណូមពរអ្នកមីងអោយអ្នកមីងនិយាយទៅកាន់កូនរបស់មីងជំនាន់ក្រោយផងហ្នឹងណាមីងដែរពួកគាត់កំពុងតែបានស្តាប់នូវភាពទុក្ខលំបាករបស់មីងហើយហ្នឹងបទពិសោធន៍ដែរល្អអ

ញ៉ឹងហ្នឹងណាអញ៉ឹងចង់សុំអោយមីងជួយនិយាយបន្តិចមកហ្នឹងណាមីងជាចុងក្រោយព្រោះបានអោយពួកគាត់ហ្នឹងណាបានរៀនសូត្រតាមអ្នកមីង។

ខ៖

ចង់អោយកូនហ្នឹងហ្នឹងថាបើសិនជាកូនហ្នឹងយើងដឹងថាម៉ែឪពុកម្ដាយយើងហ្នឹងក្រអញ៉ឹងហ្នឹងណាអោយកូនហ្នឹងខំប្រឹងរៀនព្រោះអីដូចជាបានដឹងស្រាប់ហើយណា
ម៉ែឪហ្នឹងណាសព្វថ្ងៃហ្នឹងគ្មានអ្វីទេម៉ែឪក្រណាស់មិនមានអីអោយទេមានតែចំណេះដឹងណាជួយទៅជួយអោយកូនៗហ្នឹងប្រឹងតស៊ូរៀនសូត្រទៅអោយបានការងារគ្រាន់បើបានធ្វើទៅណាហ្នឹងអែងហើយក៏វាមិនសូវជាហ៊ត់នើយដូចជាម្ដាយឪពុកដែរហ្នឹងណាព្រោះតែយើងហ្នឹងរៀនមិនបានច្រើនក៏គ្មានបានការងារណាបានធ្វើល្អហ្នឹងគេដែរហ្នឹងណាហើយតាបានធ្វើការងារល្អៗហើយគេសាញ្ញែតែមួយខ្វាច់ក៏គេបានលុយដែរហ្នឹងណាមើលទៅមើលដូចជាឪពុកម្ដាយហ្នឹងណាមកពីរគាត់រៀនមិនបានច្រើនអញ៉ឹងហើយបានជាធ្វើការមិនបានល្អហ្នឹងណាគេចេះគ្រាន់តែគេធ្វើការតែបន្តិចក៏គេបានលុយដែរណាដូចជាក្មេងសម័យឥឡូវហ្នឹងអញ៉ឹងណាចាសអញ៉ឹងបានថាចេះតែប្រាប់ៗវាទៅណាមិនចង់អោយវាពិបាកដូចជាយើងហ្នឹងណា
ហើយហ្នឹងផ្ដាំថាអោយកូនៗហ្នឹងណាខំប្រឹងធ្វើទេអំពើល្អទៅណា។

ខ៖

ហ្នឹងធ្វើតាមអ្នកមីងចាសអញ៉ឹងថ្ងៃនេះខ្ញុំសូមអរគុណអ្នកមីងដែរបានយល់ព្រមអោយនាងខ្ញុំបានធ្វើការសំភាសន៍អ្នកមីងជាលើទីពីរ។